# មេរៀនទី ៩២៖ ព្រះជួយគេឌាន

[ចៅហ្វាយ ៦៖១-១៦, ៧៖១-២៤]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/JH-s4jC1__8

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/QWsrSgBaxYY

**គោលបំណង៖** គ្មានអ្វីដែលព្រះមិនអាចធ្វើបាននោះទេ។

**ខគម្ពីរចងចាំ៖លូកា១៨៖២៧** *"ការដែលមនុស្សធ្វើមិនកើតនោះព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់"*។

**ចំរៀង** ( *យូធូបលីង* )៖

១.យើងនិងឈ្នះ https://youtu.be/Ba2UR8O5Rgw

២.ចូលមានកំឡាំងនិងចិត្តក្លាហានចុះ https://youtu.be/Mr7oyUvG7U8

៣.អ្នកក្លាហានគេឌាន https://youtu.be/RARfWowlWls

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «មិនអាចទៅរួច»

សម្ភារៈដែលត្រូវការ៖ ក្រដាសឆ្នូលរួច



១.ចែកកុមារជាពីរក្រុម ហើយគូសបន្ទាត់នៅចន្លោះក្រុមទាំងពីរ (ប្រើស្កុតក៏បាន)។

២. ដាក់ក្រដាសដែលបានឆ្នូលរួចទាំងអស់នៅចំពីលើបន្ទាត់ដែលបានកំណត់នោះ។

៣. នៅពេលដែលគ្រូស្រែកថា "១ ២ ៣ ទៅ" ក្រុមនីមួយៗ ត្រូវសហការគ្នាក្នុងការគុបក្រដាសដែលឆ្នូលរួចនោះ ទៅកាន់ក្រុមមួយទៀត។(គ្រាន់តែព្យាយាមគុបក្រដាសទៅ ក្រុម ម្ខាងទៀតតែមិនត្រូវលាក់ក្រដាសពីគ្នានោះទេ)

៤. នៅពេលដែលពួកគេកំពុងលេងហើយគ្រូដើរទៅប៉ះស្មារបស់កុមារណាម្នាក់នោះ គេត្រូវប្តូរក្រុមដោយរត់ទៅចូលក្រុមមួយទៀត។

៥.គ្រូ៖ ត្រូវប៉ះស្មារបស់ក្រុមតែម្ខាងបានហើយ រហូតដល់ក្រុមនោះនៅសល់កុមារ តែម្នាក់ឬពីរនាក់ប៉ុណ្ណោះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមសួរកុមារថា៖

ក. តើក្រុមមួយណាដែលមានក្រដាសឆ្នូលច្រើនជាង? (ក្រុមដែលមានកុមារតិច)

ខ.តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលដែលលេងល្បែងទាំងដែល ក្រុមរបស់ខ្លួនមានគ្នាតិចជាងគេបែបនេះ? (ពិបាក)

គ. តើអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលដែលអ្នកលេងល្បែង ហើយក្រុមរបស់ខ្លួនមានគ្នាច្រើនជាងគេបែបនេះ? (សប្បាយ)

ឃ. តើវាអាចទៅរួចដែលឬទេ ដែលក្រុមដែលមានគ្នាតិចឈ្នះល្បែងនេះ? ( ទេ វាមិនអាចទៅរួចនោះទេ)

៧. ថ្ងៃនេះយើងនឹងរៀនអំពីមេរៀន ពីការដែលមនុស្សមិនអាចធ្វើទៅបាន ប៉ុន្តែព្រះអាចធ្វើឲ្យវាទៅបាន!

## ៤. ការណែនាំមេរៀន

ល្បែងកំសាន្តដែលយើងទើបតែលេងរួចនេះ វាគឺជាល្បែងដែលមិនស្មើភាពនោះទេ ដែលម្ខាងមានគ្នាច្រើន ហើយម្ខាងមានគ្នាតិចនោះ។ តើមានរឿងអ្វីកើតឡើងចំពោះល្បែងនេះ វាមើលទៅស្រដៀងទៅនឹងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងព្រះគម្ពីរដែរ ដែលនិយាយអំពី គេឌាន និងទាហានរបស់គាត់។ ប៉ុន្តែពួកគេបានដឹងថា គ្មានអ្វីដែលមិនអាចទៅរួចសម្រាប់ព្រះឡើយ។ តោះសូមឲ្យយើងបានក្រឡេកទៅមើលពីអ្វីដែលបានកើតឡើងនៅក្នុងព្រះគម្ពីរទាំងអស់គ្នា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះគម្ពីរបានប្រាប់យើងអំពីពេលវេលាដែលជនជាតិអ៊ីស្រាអ៊ែលបានទាស់ប្រឆាំងជាមួយព្រះ និងបានដើរចេញពីផែនការរបស់ព្រះ។ ព្រះបានអនុញ្ញាតឲ្យពួកម៉ាឌានវាយបំបាក់ពួកអ៊ីស្រាអែល។ ពួកម៉ាឌានបានបំផ្លាញផលដំណាំ និងទីបោះទ័ពរបស់ជនជាតិអ៊ីស្រាអែល។ ជនជាតិអ៊ីស្រាអែលបានធ្លាក់ខ្លួនក្រ និងរងទុក្ខវេទនា។

ចុងបញ្ចប់ជនជាតិអ៊ីស្រាអែលបាននឹកចាំពីព្រះ ហើយក៏ស្រែកអង្វររកទ្រង់។ ព្រះបានឮការអធិស្ឋានរបស់ពួកគេ ហើយបានចាត់មនុស្សម្នាក់ឱ្យរំឭកពួកគេអំពីព្រះចេស្ដាដ៏ខ្លាំងក្លានៃព្រះរបស់ពួកគេ។ ហើយព្រះអង្គ បានជ្រើសរើសបុរសម្នាក់ដែលមានឈ្មោះថា គេឌាន។ គេឌានគឺជាបុរស ទន់ខ្សោយម្នាក់ដែលមកពីកុលសម្ព័ន្ធតូចមួយ ប៉ុន្តែគាត់បានយល់ព្រមធ្វើតាមផែនការរបស់ព្រះ។ គេឌានបានប្រមូលទ័ព ៣២,០០០នាក់ ដើម្បីប្រយុទ្ធនឹង ពួកម៉ាឌាន ប៉ុន្តែព្រះមានបន្ទូលថា វាច្រើនពេកហើយ។

បន្ទាប់មកព្រះបានមានបន្ទូលប្រាប់ គេឌានឲ្យបញ្ជូនពួកអ្នកដែលមិនហ៊ានច្បាំងជាមួយពួកម៉ាឌាន ឲ្យត្រឡប់ទៅផ្ទះវិញ។ បន្ទាប់មកមានកងទ័ព ២២,០០០នាក់បានត្រឡប់ទៅផ្ទះវិញ។ ដូច្នេះ គេឌានមានទ័ពតែ ១០,០០០ នាក់ប៉ុណ្ណោះក្នុងការច្បាំងជាមួយពួកម៉ាឌាន។ ប៉ុន្តែព្រះបានមានបន្ទូលថា នៅតែមានចំនួនច្រើនដដែល។ ព្រះពិតជាចង់ឲ្យជនជាតិអ៊ីស្រាអែលដឹងថា គឺអំណាចដ៏ខ្លាំងក្លារបស់ព្រះទេ ដែលបានសង្គ្រោះពួកគេ មិនមែនជាចំនួនទាហានដ៏ច្រើននោះឡើយ។

ដូច្នេះ ព្រះបានឲ្យគេឌាននាំកងទ័ពទាំងអស់ចុះទៅផឹកទឹក ហើយទុកតែអ្នកដែលផឹកទឹកដោយប្រើដៃក្បង់ប៉ុណ្ណោះ។ នៅពេលដែលព្រះបានជម្រើសពួកទាហានរួច នោះគឺនៅសល់តែ ៣០០ នាក់ប៉ុណ្ណោះក្នុងជួរកងទ័ពអ៊ីស្រាអែល។ ចំណែកកងទ័ពម៉ាឌានមានគ្នាច្រើនជាងនេះឆ្ងាយណាស់។

ជាធម្មតា វានឹងមិនអាចទៅរួចនោះទេ សម្រាប់កងទ័ពដែលមានគ្នាតិច ដើម្បីផ្ដួលកងទ័ពដែលមានគ្នាច្រើននោះ ប៉ុន្តែត្រូវចាំថា នេះជាផែនការរបស់ព្រះ មិនមែនជាផែនការរបស់គេឌានទេ។ ព្រះបានប្រាប់គេឌាន និងមនុស្ស ៣០០នាក់ របស់គាត់ឲ្យផ្លុំត្រែនៅដៃស្ដាំ រួចកាន់ចន្លុះនៅដៃឆ្វេង និងបំបែកក្អម ដើម្បីបន្លឺសំឡេងឲ្យឮខ្លាំងនៅពេលយប់។

នៅពេលឮសំឡេងខ្លាំង ពួកម៉ាឌានក៏ស្ទុះឡើងទៅប្រយុទ្ធ ប៉ុន្តែព្រះបានបញ្ឆោតពួកគេ។ ពួកគេបានវាយសម្លាប់គ្នាឯងទៅវិញទៅមក ដោយនឹកស្មានថាវាយជាមួយពួកគេឌាន បន្ទាប់មកពួកគេក៏រត់ខ្ចាត់ខ្ចាយអស់ទៅ។ ដោយមានជំនួយពីព្រះ កងទ័ពរបស់គេឌានដែលមានគ្នាតិចបានឈ្នះ។ ជនជាតិអ៊ីស្រាអែលក៏បានសង្គ្រោះទៅ!

ព្រះបានបង្ហាញជនជាតិអ៊ីស្រាអែលថា គ្មានអ្វីដែលទ្រង់មិនអាធ្វើបាននោះទេ។ ជនជាតិអ៊ីស្រាអែលបានរៀនពីការនេះថា ពួកគេអាចធ្វើអ្វីក៏បានដោយមានជំនួយពីព្រះ។ សូមចាំថា យើងអាចធ្វើបានគ្រប់ការទាំងអស់ ប្រសិនបើយើងមានព្រះគង់ជាមួយយើង។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាព្រះអនុញ្ញាតឲ្យពួកម៉ាឌានវាយប្រហារជនជាតិអ៊ីស្រាអែល? *(ជនជាតិអ៊ីស្រាអែលបានទាស់នឹងព្រះ ហើយដើរចេញពីផែនការរបស់ទ្រង់)*
២.តើជនជាតិអ៊ីស្រាអែលបានធ្វើអ្វីខ្លះ ពេលដែលពួកគេធ្លាក់ខ្លួនក្រ និងវេទនា? *(ពួកគេនឹកចាំហើយស្រែកអង្វរទៅកាន់ព្រះ)*
៣.តើព្រះបានលើកអ្នកណាជាអ្នកដឹកនាំ? *(គេឌាន)*
៤.ហេតុអ្វីបានជាព្រះចង់ឲ្យមនុស្សតែ៣០០នាក់តទល់នឹងពួកម៉ាឌាន? *(ព្រះមិនចង់ឲ្យអ៊ីស្រាអែលគិតថាពួកគេឈ្នះដោយសារតែកងទ័ពច្រើននោះទេ)*
៥.តើអ្វីជាផែនការរបស់ព្រះ? *(ព្រះបានឲ្យមនុស្ស ៣០០នាក់ផ្លុំត្រែ និងបំបែកក្អម ដើម្បីឲ្យពួកម៉ាឌានភ្ញាក់ផ្អើល ហើយបន្ទាប់មកទ្រង់បានបញ្ឆោតពួកម៉ាឌាន ដូច្នេះពួកគេបានសម្លាប់គ្នាឯងទៅវិញទៅមក)*
៦.តើមានការអ្វីដែលព្រះមិនអាចធ្វើបានដែរឬទេ? *(គឺគ្មានទេ! ព្រះអាចធ្វើបានគ្រប់ការទាំងអស់)*

## ៧. ល្បែងកំសាន្ត «បញ្ជូនគ្រាប់សណ្តែកដី»

សម្ភារៈដែលត្រូវការ៖ ចាន៤. ទុយោបឺតសម្រាប់កុមារគ្រប់ៗគ្នា. សណ្តែកដី និងកៅអី៤




១.ចែកកុមារជាពីរក្រុមស្មើគ្នា ហើយឲ្យទុយោដល់កុមារគ្រប់គ្នាៗ
២.ដាក់គ្រាប់សណ្តែកដីនៅក្នុងចានលើកៅអីម្ខាង ហើយចានទទេ នៅកៅអីម្ខាងទៀត
៣. កុមារត្រូវបឺតគ្រាប់សណ្តែក ដោយមិនប្រើដៃម្នាក់ម្តងៗ។ គ្រូជាអ្នកកំណត់ពេលវេលា ក្រុមណាបឺតបានគ្រប់សណ្តែកដាក់ចូលក្នុងចានបានច្រើនជាងគេនឹងឈ្នះល្បែងនេះ។
៤.តាមរយៈល្បែងនេះសូមពន្យល់កុមារថា ទោះបីជាការងារនោះមើលទៅពិបាកខ្លាំងប៉ុនណាក៏ដោយ ក៏ព្រះអាចធ្វើបានគ្រប់ការទាំងអស់។

## ៨. ខគម្ពីរចងចាំ

**លូកា ១៨៖២៧** *"ការដែលមនុស្សធ្វើមិនកើត នោះព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់"*។

## ៩. ហត្ថកម្ម «ត្រែរបស់គេឌាន»

សម្ភារៈដែលត្រូវការ៖ កន្ត្រៃ, កាវបិត, ក្ដូរ័រ និងបោះពុម្ពរូបភាពត្រែ (នៅទំព័រខាងក្រោម)



១. សូមបោះពុម្ពរូបភាពត្រែសម្រាប់សិស្សគ្រប់ៗគ្នា
២. ឲ្យពួកគេផាត់ពណ៌លើរូបត្រែនោះ



៣. ឲ្យកុមារកាត់រូបត្រៃចេញមក ហើយបិតមុខកាត់ទាំង ពីរភ្ជាប់គ្នា។

៤.ពេលកុមារគ្រប់គ្នាធ្វើរួចហើយ សូមឲ្យពួកគេសូត្រខគម្ពីរចងចាំ ដោយប្រើត្រៃរបស់ ពួកគេ។ (ជម្រើសៈ កុមារអាចដាក់ទុយោនៅខាងក្នុងត្រៃ ដែលអាចផ្តុំឲ្យឮសម្លេងបាន។)

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ពេលយើងមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវ មិនថាមានអ្វីកើតឡើងចំពោះយើងទេ យើងអាចប្រាកដចិត្តបានថា ទ្រង់គង់នៅទីនោះជាមួយយើង។ មិនថាពេលខ្លះយើងពិបាកចិត្តឬមានអារម្មណ៍ថាព្រះទ្រង់នៅឆ្ងាយពីយើងក៏ដោយ តែព្រះនៅតែគ្រប់គ្រងយើង។ សូមគិតត្រឡប់ក្រោយបន្តិច អំពីគេឌាន ដែលគាត់មានអារម្មណ៍ថា ខ្លួនគាត់មិនល្អគ្រប់គ្រាន់។ តើនៅពេលណាដែលអ្នកមានអារម្មណ៍បែបនេះ? តើពេលណាដែលអ្នកមានអារម្មណ៍ថា ខ្លួនឯងមិនល្អគ្រប់គ្រាន់ក្នុងតួនាទីជាគ្រូបង្រៀន? តើព្រះបានជួយអ្នកដោយរបៀបណា? តើបទពិសោធន៍នោះបានជួយបង្កើនជំនឿរបស់អ្នកយ៉ាងដូចម្តេច? លើកក្រោយ នៅពេលដែលអ្នកមានអារម្មណ៍ថា ខ្លួនអ្នកល្អមិនគ្រប់គ្រាន់ ចូរពឹងផ្អែកលើសេចក្តីជំនឿរបស់អ្នក ហើយឆ្ពោះទៅមុខដោយភាពជឿជាក់។

# ត្រែរបស់គេខ្វាន

